# សេចក្តីអំពាវនាវ

ខ្ញុំបាទ យ៉ង់ ច័ន្ទសុវណ្ណមានរិទ្ធិ ជាបុគ្គលិក UNTAC នៅកម្ពុជាផ្នែកគណៈធិបតីជំនួញកិច្ចការបោះឆ្នោត នៅមណ្ឌល អំពៅព្រៃ ស្រុកពាមរក៍ ខេត្តព្រៃវែង រស់នៅភូមិអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង។ មានកិត្តិយស សូមជំរាបចូលកមវិទ្យុ អ.ស.ប untac នៅកម្ពុជា មេត្តាជួយផ្សព្វផ្សាយលិខិតខ្ញុំបាទជូនសង្គម

កម្ពុជា។

យោងតាមកម្មវិធីបោះឆ្នោតនៅកម្ពុជា ជាប្រវត្តិសាស្ត្រនាថ្ងៃទី ២៣ ឧសភា ១៩៩៣ រហូតដល់ថ្ងៃ ២៨ ឧសភា ១៩៩៣ និងសកម្មភាពនៃការរាប់សន្លឹកឆ្នោតឬការផ្សព្វផ្សាយលទ្ធិផល នៃទូរលេខនៃការរាប់សន្លឹក ឆ្នោត untac ទូទៅតាមខេត្តនីមួយៗ នៃវិទ្យុ untac នោះ តាមមហន្តរាយនៃសង្គមត្រូវហែលនូវវិបត្តិគួរអោ យរន្ធត់ និងអាសូពន់ពេក មូលហេតុនៃហេតុនៃហតុការណ៍នេះ ទើបខ្ញុំបាទ ខ្ញុំព្រះករុណា ទូលបង្គំ សរសេរនូវ កូនលិខិតមួយតូចសូមវន្ទាដល់សង្គមកម្ពុជាមេត្តាអ្នកបញ្ចប់នូវទស្សនៈអាត្មានិយមមកប្រើទស្សនៈសិក្សារួម ទើបមានសន្តិភាពសំរាប់កូនចៅជាន់ក្រោយ។ សកម្មភាពមាន៖

1. មិត្តភក្តិក្លាយជាសត្រូវនឹងគ្នា ឬគូរឆាំងនយោបាយ
2. បងប្អូនបែកបាក់ភាពសាមគ្គី
3. ប្តីប្រពន្ធព្រាត់ប្រាស់គ្នា

ជនរួមជាតិជាទីគោរព បុព្វចារ្យ លោកគ្រូ រៀមច្បង គ្រប់ប្រភេទជាទីស្នេហា។ ការស្គាល់នូវ

- មិត្តភាព កល្យាណមិត្ត
- ការចិញ្ចឹម រក្សា សាមគ្គីភាពក្រុមគ្រួសារបងប្អូន
- ការរៀបចំនូវភរិយា ស្វាមីសំរាប់សុភមង្គល

កត្តាទាំងបីខាងលើនេះ តើវាជាកំសាន្តមួយនៃល្បែងជីវិតឬអ្វី? មិនពិតទេ! នេះហេតុអ្វីទៅហ្ន៎?

ជនរួមជាតិជាទីគោរពនៅក្នុងសង្គមមួយត្រូវមានការចាំបាច់ការសាមគ្គី មិត្តភាព ទំនាក់ទំនងពី មជ្ឈមណ្ឌលមួយទៅមួយទៀត។ ជនរួមជាតិមេត្តា បញ្ឈប់នូវសកម្មភាពដូចដែលខ្ញុំជួបហើយ មានឧទាហរណ៍ មកខាងលើនេះស្រាប់ ហេតុអ្វីទៅហ្ន៎? ព្រោះថាមិត្តភក្តិនៅជាមិត្តភក្តិ បងប្អូននៅតែជាបងប្អូន ហើយប្តីប្រពន្ធក៏ នៅតែប្តីប្រពន្ធដដែល។ បានជាខ្ញុំហ៊ានពោលថាដូច្នេះ ព្រោះថា មនុស្សទូទៅតែងមានទស្សនៈគតិ ចំណង់ចិត្ត ផ្សេងៗគ្នា ហើយខ្លះចូលចិត្តសាប ប្រៃ ល្វីង ជូរ ចិត្តស្រឡាញ់ពណ៌ស ខ្មៅ ខៀវ ក្រហម។ល។ ហេតុអ្វី? បានជា

គេនូវតែរស់នៅជុំគ្នាបាន ហូបពិសាជុំគ្នាបាននោះ ដោយការយល់កា ឬរៀបចំរបស់យើង។ ពេលនេះវាមិនខុសគ្នាទេ បើរូបអ្នកស្រឡាញ់គណបក្សមួយ អ្នកស្រឡាញ់មួយផ្សេង ទោះកូនក្តី ឪពុកម្តាយក្តី ប្តីប្រពន្ធក្តី មិត្តភក្តិឬសាច់ញាតិ មិត្តអ្នកក្តី វាជាមនោសញ្ចេតនារបស់តាមមតិយល់ឃើញរបស់គេម្នាក់ៗ និងជាសម្បទានការកសាងសង្គមជាតិតាមទស្សនៈរបស់គេនៅពេលបោះឆ្នោតនេះ គឺពិសេសសន្លឹកឆ្នោតរបស់គនោះតែម្តង។ ដូច្នេះហើយក្នុងករណីមាតុភូមិសុខសន្តិភាព និងការកើតឡើងនូវការគុំគួន នៃកំហឹង រវាងគ្នានិងគ្នានោះដែលនាំមកមហន្តរាយសង្គមជាតិ ដូចអស់លោកជនរួមជាតិបានជួបមកហើយនៃរយកាល២០ឆ្នាំនេះ បណ្តាលមកពីអ្វីទៅ? មួយអ្នកគ្មានគោរពសិទ្ធិនុស្ស? គ្មានសាមគ្គីភាព?គ្មានបរិយាកាសទុកចិត្តរវាងខ្មែរនិងខ្មែរ។

សូមជនរួមជាតិមេត្តាចូលរួមទោះលោកអ្នកស្ថិតនៅលើទស្សៈការគាំពារដល់គណបក្សណាក៏ដោយត្រូវចាត់ទុកថាជាខ្មែរតែមួយ។ ដោយរក្សាទឹកចិត្តជាអ្នកកីឡា បើចាញ់ថ្ងៃនេះត្រូវយកឈ្នះវិញតាមបច្ចកទេសសមត្ថភាព ពេលប្រកួតពេលក្រោយតាមការត្រួតពិនិត្យជាសាធារណៈ និងសន្តិភាព សន្តិវិធី។ យើងសង្ឃឹមថាជនរួមជាតិពិតជាសិក្សាហេតុផលនេះ ហើយនៅថ្ងៃអនាគតពិតជាមានសន្តិភាពជានិរន្តរ៍លើមាតុភូមិកម្ពុជា។

សូមជនរួមជាតិមេត្តាជួបនូវពន្លឺ សាមគ្គីភាព មិត្តភាព សន្តិភាពទៅអនាគតនិងទទួលនូវសេចក្តីសុខតាមគ្រួសារ ញាតិរៀងៗខ្លួន។

ធ្វើនៅថ្ងៃទី 21.6.1993

សូមជំរាបលោក គង់សំរេច មេត្តាជួយចាក់បទចំរៀងមួយបទផ្ញើជូនអ្នកស្តាប់សំលេងផ្សាយនៃវិទ្យុ UNTAC បន្ទាប់លោកបានអានចប់នូវលិខិតរបស់ខ្ញុំរួចហើយនោះ បទនោះគឺពង្សាវតាខ្មែរ និពន្ធដោយសម្តេចសង្ឃរាជ ជួន ណាត ច្រៀងដោយលោក ស៊ីន ស៊ីសាមុត ខ្ញុំសង្ឃឹមថាលោកពិតជាជួយសំរួលខ្ញុំបាទនិងជូនសង្គមកម្ពុជា។

សូមលោក និងសហការីវិទ្យុអ៊ុន តាក់បានទទួលនូវជោគជ័យរាល់បេសកម្មរបស់ខ្លួនតរៀងទៅគ្មានថ្ងៃបញ្ចប់ឡើយ។

ធ្វើថ្ងៃទី 21.6.1993

ហតត្ថលេខា

យ៉ង់ ច័ន្ទសុវណ្ណមានរិទ្ធិ

បញ្ជាក់ជូន៖ សូមកុំប្រើឈ្មោះតាមលិខិតនេះនៅពេលផ្សព្វផ្សាយ (សូមអរគុណ)

<u>ពាក្យសំណើសុំ</u>

ខ្ញុំបាទឈ្មោះ យ៉ង់ សុវណ្ណមានរិទ្ធិ ជាបុគ្គលិករបស់ UNTAC ជាមន្ត្រីគណៈអធិបតីជំនួយនៅឯមណ្ឌលបោះឆ្នោត ភូមិសំពៅព្រៃ ឃុំកោះសំពៅ ស្រុកពាមរក៍ ខេត្តព្រៃវែង។

<u>សូមគោរពចូលមក</u>

លោកនាយកវិទ្យុ អ.ស.ប UNTAC នៅកម្ពុជា សូមជ្រាប

កម្មវត្ថុះ ស្ដីពីសំណើសុំចំពោះវិទ្យុនៃ អ.ស.ប UNTAC នៅកម្ពុជា តាមកម្មវិធីដូចមានះ

1. ការសុំចាក់បទចំរៀងតាមសំណើសុំ
2. ការសុំអោយជួយផ្សាយនូវអត្ថបទ
3. ការសុំអោយការជូនដំណឹង

អាស្រ័យដូចមានជូនមកខាងលើនេះ សូមលោកមេត្តាជួយសំរួលតាមការសុំតាមការគួរនិងអនុគ្រោះ។

សូមលោកនាយកវិទ្យុនៃ អ.ស.ប UNTAC នៅកម្ពុជាមេត្តាទទួលនូវសេចក្ដីគារវកិត្តិភាពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅថ្ងៃទី 21. 6. 1993

ហត្ថលេខា